**Cambodian - Insect Bites**

ការកើតមានដាហ្វូង



# សត្វល្អិតខាំ

## ចំណុចសំខាន់ៗ

- សត្វល្អិតខាំភាគច្រើន កើតមាននៅកន្លែងឥតមានគ្របដណ្តប់ដូចជាមុខ ឬ ដៃ
- ជួនកាលសត្វល្អិតខាំកើតមានជាក្រុមនៅលើដងខ្លួន ជាកន្លែងដែលសត្វល្អិតបានលូនវានៅក្រោមសំល្បេកបំពាក់
- កំដៅអាចធ្វើឲ្យរមាស់កើតមានកាន់តែធ្ងន់ធ្ងរឡើង
- ការដាក់ឲ្យត្រជាក់នៅត្រង់កន្លែងសត្វល្អិតខាំ និងជូតមុខឲ្យសើមជាមួយកូនកន្សែង អាចជួយបន្ធូរនៅត្រង់កន្លែងដែលខាំនោះ
- ក្រែម antihistamine (ក្រែមប្រឆាំងប្រតិកម្មជាតិពុល) អាចជួយបន្ធូរ ក៏ប៉ុន្តែសូមឃ្លាំមើលក្រែងលោកើតមានប្រតិកម្មជំទាស់
- ថ្នាំទឹកស៊ីរ៉ូម antihistamine (ថ្នាំទឹកស៊ីរ៉ូមប្រឆាំងប្រតិកម្មជាតិពុល) អាចជួយបន្ធូរនៅពេលយប់
- ប្រសិនបើមានដាច់ស្បែកដោយសារការអេះ សូមប្រើថ្នាំសម្លាប់មេរោគដើម្បីការពារកុំឲ្យវាក្លាយ

## តើវាជាអ្វី?

សត្វល្អិតខាំគឺជាប្រតិកម្មទៅនឹងជាតិពុលនៅត្រង់កន្លែងស្បែកណាមួយ ដែលសត្វល្អិតប្រភេទផ្សេងៗ វាខាំចូលទៅក្នុងស្បែក។ សត្វល្អិតខាំតែងកើតមានជាទូទៅ ហើយក្មេងខ្លះឆាប់ក្លាយជាងក្មេងដ៏ទៃទៀត។ សត្វល្អិតវាខាំតិចៗ ឬច្រើនដងដែលស្នាមរមាស់ស្ថិតនៅលើស្បែកអស់រយៈពេលពីរ ឬបីថ្ងៃ។ ពេលខ្លះការខាំទាំងនោះបង្កើតទៅជាពងខ្ទុះ ជាពិសេសនៅលើជើង។

## វាកើតឡើងមាននៅកន្លែងណា?

សត្វល្អិតខាំភាគច្រើនកើតមាននៅកន្លែងឥតមានគ្របដណ្តប់ ជាកន្លែងដែលសត្វល្អិតអាចលូនវាទៅដល់ស្បែក។ សត្វល្អិតខាំពេលខ្លះអាចកើតមានជាក្រុមនៅលើដងខ្លួន ជាកន្លែងដែលសត្វល្អិតអាចលូនវានៅក្រោមសំល្បេកបំពាក់។

ជួនកាលកូនក្មេងអាចកើតមានប្រតិកម្មដោយសារសត្វល្អិតខាំ។ បន្ទាប់មកវាក៏បង្កើតទៅជាស្នាម នៅឆ្ងាយពីកន្លែងដើមដែលវាខាំកូនក្មេង ដែលមើលទៅដូចជាសត្វល្អិតខាំ។ ឧទាហរណ៍ សត្វល្អិតខាំនៅជើងអាចនាំឲ្យកើតមានស្នាមនៅលើដងខ្លួន និងដៃជើងផ្នែកខាងលើ។ ស្នាមទាំងនេះនឹងបាត់ទៅដោយឯង ក៏ប៉ុន្តែអាចកើតឡើងវិញ ប្រសិនបើសត្វល្អិតដដែលនោះខាំកូនក្មេង។

## វាគេព្យាបាលវាដោយរបៀបណា?

លក្ខណៈពិសេសនៃសត្វល្អិតខាំគឺរមាស់។ រមាស់នេះនឹងកើតមានកាន់តែធ្ងន់ធ្ងរឡើងនៅពេលមានកំដៅ។ ការដាក់ឲ្យត្រជាក់នៅត្រង់កន្លែងសត្វល្អិតខាំ និងជូតមុខឲ្យសើមជាមួយកូនកន្សែង អាចជួយបន្ធូរនៅត្រង់កន្លែងដែលខាំនោះ។ កូនក្មេងខ្លះបានទទួលការបន្ធូរដោយប្រើថ្នាំទឹក calamine lotion (ថ្នាំទឹកលាបស្បែករលាក) ឬថ្នាំធ្វើឲ្យត្រជាក់ឯទៀតនៅពីលើស្បែក។

គេអាចប្រើក្រែម antihistamine យូរៗម្តងបាន ក៏ប៉ុន្តែវាអាចបណ្តាលឲ្យកើតមានប្រតិកម្មរលាកស្បែក។ ប្រសិនបើកើតមានកន្ទួលនៅត្រង់កន្លែងលាបក្រែមលើស្បែក ត្រូវឈប់ប្រើវាភ្លាម។ ការប្រើថ្នាំទឹកស៊ីរ៉ូម antihistamine យូរៗម្តង ដែលបញ្ជាដោយវេជ្ជបណ្ឌិតប្រចាំគ្រួសារ អាចមានប្រសិទ្ធិភាព ប្រសិនបើរមាស់នោះវាកើតមានធ្ងន់ធ្ងរ ហើយធ្វើឲ្យក្មេងភ្ញាក់នៅពេលយប់។

អាចកើតមានសភាពគ្រោះថ្នាក់នៃមេរោគបាក់តេរីបណ្តាលមកពីសត្វល្អិតខាំ ប្រសិនបើអេះខ្លាំងពេក ហើយបណ្តាលឲ្យចេញទឹក ហើយកើតមានក្រមរនៅត្រង់កន្លែងខាំនោះ។ នៅក្នុងករណីនេះ ជាចាំបាច់គេអាចប្រើថ្នាំសម្លាប់មេរោគដើម្បីការពារកុំឲ្យក្លាយ។

សត្វល្អិតខាំភាគច្រើនធូរស្បើយក្នុងរយៈពេលពីរ ឬបីថ្ងៃ។ ប្រសិនបើស្នាមរមាស់ចេះតែកើតមានឥតដាច់ ឬស្នាមជាច្រើនចេះតែកើតមាន នេះគឺជាការចាំបាច់ដែលត្រូវស្វែងរកឱវាទពីវេជ្ជបណ្ឌិត ដើម្បីឲ្យបានដឹងច្បាស់ថាស្នាមទាំងនោះមិនបណ្តាលមកពីអ្វីផ្សេងពីសត្វល្អិតខាំ។

## ពត៌មានបន្ថែមទៀត

- គិលានុបដ្ឋាយិកាមើលថែទាំសុខភាពមាតា និងកុមារ
- ឱសថការីរបស់លោកអ្នក
- វេជ្ជបណ្ឌិតប្រចាំគ្រួសាររបស់លោកអ្នក

© 2002, Department of Dermatology, St. Vincent's Hospital Melbourne, Victoria Parade, Fitzroy, Victoria 3065 Australia.